# សេចក្តីថ្លែងការណ៍ស្តីពី ការចូលយកព័ត៌មានក្នុងតំបន់ក្រហមរបស់អ្នកសារព័ត៌មាននៅកម្ពុជា

ថ្ងៃទី ៦ ខែឧសភា ឆ្នាំ ២០២១ -- យើងខ្ញុំដែលជាអង្គការ-សមាគមអ្នកសារព័ត៌មាន ដែលមានរាយនាមខាងក្រោម សូមអំពាវនាវឱ្យក្រសួងព័ត៌មានស្តារឡើងវិញនូវសិទ្ធិរបស់អ្នកសារព័ត៌មានក្នុងការចូលទៅយកព័ត៌មានដោយសុវត្ថិភាពនៅតំបន់ក្រហមក្នុងរាជធានីភ្នំពេញ។

អ្នកសារព័ត៌មានឯករាជ្យមួយចំនួនបានបង្ហាញថា ពួកគេបានត្រៀមខ្លួនទទួលយកហានិភ័យ និងចាត់វិធានការការពារខ្លួនដែលចាំបាច់យ៉ាងម៉ត់ចត់ដើម្បីចុះយកព័ត៌មានក្នុងតំបន់ក្រហមទៅតាមវិធីដែលអាចការពារខ្លួនពួកគេ និងការពារសុវត្ថិភាពសាធារណៈបាន។ លទ្ធភាពរបស់អ្នកសារព័ត៌មានក្នុងការផ្លាស់ទីដោយសេរីទៅក្នុងតំបន់ទាំងនេះមានភាពចាំបាច់ណាស់ដល់ការងាររបស់ពួកគេក្នុងការផ្តល់ព័ត៌មានជូនដល់សាធារណជន។

ប៉ុន្តែការដកហូតសិទ្ធិសេរីភាពរបស់អ្នកសារព័ត៌មាននាពេលថ្មីៗនេះក្នុងការចូលយកព័ត៌មានក្នុងតំបន់ក្រហមបានរឹតត្បិតសិទ្ធិរបស់ពួកគេក្នុងការរាយការណ៍ដោយសេរី និងយុត្តិធម៌។

ក្រៅពីការរឹតត្បិតសិទ្ធិរបស់អ្នកសារព័ត៌មានចូលក្នុងតំបន់ក្រហម ការសម្រេចផ្តល់ការអនុញ្ញាតចូលទៅតំបន់លឿងទុំសម្រាប់តែអ្នកសារព័ត៌មានដែលត្រូវបានអនុញ្ញាតដោយរដ្ឋាភិបាល បានដាក់កម្រិតលើលំហូរព័ត៌មានខណៈការផ្តល់ព័ត៌មានទៅសាធារណជនគឺជាគន្លឹះក្នុងការគ្រប់គ្រងការរីករាលដាលនៃជំងឺកូវីដ១៩ ។ ហេតុដូច្នេះអ្នកសារព័ត៌មានទាំងអស់ដែលប្រកាន់ខ្ជាប់នូវវិធានការសុខាភិបាល គោលការណ៍វិជ្ជាជីវៈ និងក្រមសីលធម៌គួរតែត្រូវបានអនុញ្ញាតឱ្យចូលយកព័ត៌មានក្នុងតំបន់ក្រហមនិងតំបន់លឿងទុំ។

លើសពីនេះទៅទៀត ការរឹតត្បិតនេះធ្វើឱ្យប៉ះពាល់ដល់ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការការពារសេរីភាពសារព័ត៌មាន និងការទទួលបានព័ត៌មាន។

អ្នកសារព័ត៌មានទាំងអស់ ទាំងអ្នកសារព័ត៌មានបម្រើការតាមស្ថាប័ន ទាំងអ្នកសារព័ត៌មានឯករាជ្យមិនមានស្ថាប័ន (freelance journalists) ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការប្រយុទ្ធប្រឆាំងនឹងព័ត៌មានមិនពិត ហើយគួរតែទទួលបានសិទ្ធិស្មើគ្នាក្នុងការចូលយកព័ត៌មានក្នុងតំបន់ហាមឃាត់។ សាធារណជនត្រូវការព័ត៌មានបន្ថែមទៀត

មិនមែនតិចជាងមុនទេ ពីសំណាក់ប្រភពព័ត៌មានផ្សេងៗដែលឯករាជ្យ និងគួរឱ្យទុកចិត្តបាន ជុំវិញវិបត្តិសុខភាពដែលកំពុងបន្តកើតមាននេះ។

ដូច្នេះ យើងខ្ញុំសូមអំពាវនាវដល់ក្រសួងព័ត៌មាន មេត្តាអនុញ្ញាតឱ្យប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងអ្នកសារព័ត៌មានឯករាជ្យមិនមានស្ថាប័ន (freelance journalists) បំពេញមុខងាររបស់ពួកគេនៅទូទាំងតំបន់ក្រហម តំបន់លឿងទុំ និងតំបន់លឿង។ អ្នកសារ-ព័ត៌មានដែលមានបណ្ណបញ្ជាក់អត្តសញ្ញាណនៅមានសុពលភាព ដែលប្រកាន់ខ្ជាប់នូវវិធានការគម្លាតសង្គមយ៉ាងតឹងរឹង ដែលពាក់ម៉ាស់ និងមានការប្រុងប្រយ័ត្នខ្ពស់ ត្រូវតែទទួលបានការអនុញ្ញាតឱ្យបន្តការងាររបស់ពួកគេដោយប្រក្រតី។

ក្នុងនាមជាអ្នកសារព័ត៌មាន យើងជឿជាក់ថាការផ្តល់ព័ត៌មានត្រឹមត្រូវ ឆ្លងកាត់ការផ្ទៀងផ្ទាត់ និងមិនលម្អៀង គឺជាសេវាកម្មសាធារណៈដ៏ចាំបាច់មួយ ហើយយើងខ្ញុំសូមជំរុញដល់ក្រសួងព័ត៌មានមេត្តាអនុញ្ញាតឱ្យអ្នកសារ-ព័ត៌មានឯករាជ្យទាំងជនជាតិកម្ពុជា និងជនបរទេស អាចបន្តបំពេញតួនាទីដ៏សំខាន់នេះ៕

អង្គការ-សមាគមដែលបានចុះហត្ថលេខា

១. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)

២. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA)

៣. សហព័ន្ធអ្នកសារព័ត៌មានអន្តរជាតិ (IFJ)

៤. ក្លឹបអ្នកសារព័ត៌មានបរទេសនៃកម្ពុជា (OPCC)